# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ [illegible] សហវ.ប្រក

## ប្រកាស
## ស្តីពី
## វិធាន និងនីតិវិធីចំណាយប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩និងមាត្រា១០នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត-ក្រុង-ក្រុងស្វយ័ត-រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១._**

ប្រកាសនេះ កំណត់អំពីវិធាន និងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ២._**

ប្រកាសនេះមានវិសាលភាពគ្របដណ្តប់លើការអនុវត្តប្រាក់បេសកកម្ម ទាំងនៅក្នុងប្រទេស ទាំងទៅក្រៅប្រទេស រួមទាំងការកំណត់សោហ៊ុយធ្វើដំណើរសម្រាប់បេសកកម្មក្នុងប្រទេស សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ប្រកាសនេះ មិនអនុវត្តចំពោះទីប្រឹក្សា ឬជំនួយការ ដែលមានឋានៈបន្ថែមលើមុខងារក្រៅពីប្រព័ន្ធនៃរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ មន្ត្រីភូមិ ជំនួយការរដ្ឋបាលឃុំ/សង្កាត់ មន្ត្រីជាប់កិច្ចសន្យាដែលមិនមានការទទួលស្គាល់ជាផ្លូវការដោយក្រសួងមុខងារសាធារណៈ។

## ជំពូកទី២

## សោហ៊ុយធ្វើដំណើរសម្រាប់បេសកកម្មនៅក្នុងប្រទេស

**ប្រការ៣._**

សោហ៊ុយធ្វើដំណើរសម្រាប់បេសកកម្មនៅក្នុងប្រទេសត្រូវផ្តល់ជូនជាសាច់ប្រាក់ អាស្រ័យលើមធ្យោបាយធ្វើដំណើរ និងចម្ងាយនៃការធ្វើដំណើរ ក្នុងការបំពេញបេសកកម្មនៅក្នុងប្រទេស។

ការជ្រើសរើសប្រើប្រាស់មធ្យោបាយធ្វើដំណើរណាមួយ ត្រូវសម្រេចដោយអនុលោមតាមគោលការណ៍វិចារណកម្មចំណាយ និងសន្សំសំចៃ។

**ប្រការ៤._**

សោហ៊ុយធ្វើដំណើរត្រូវបានកំណត់តាមមធ្យោបាយធ្វើដំណើរ ដូចខាងក្រោម÷

- ក្នុងករណីប្រើប្រាស់មធ្យោបាយធ្វើដំណើររបស់រដ្ឋ ឬផ្ទាល់ខ្លួន សោហ៊ុយធ្វើដំណើរត្រូវផ្តល់ជូនដូចខាងក្រោម÷
  - សាច់ប្រាក់ចំនួន ៨០ ០០០(ប្រាំបីម៉ឺន)រៀល ក្នុង១០០ គីឡូម៉ែត្រ សម្រាប់រថយន្តមួយគ្រឿង ឬ ២៥ ០០០(ពីរម៉ឺនប្រាំពាន់)រៀល ក្នុង១០០ គីឡូម៉ែត្រ សម្រាប់ទោចក្រយានយន្តមួយគ្រឿង
  - សោហ៊ុយធ្វើដំណើរត្រូវគណនាជាសាច់ប្រាក់ទៅតាមចម្ងាយធ្វើដំណើរជាក់ស្តែងតាមគោលការណ៍សមាមាត្រធៀបនឹងចំនួនដែលបានកំណត់ខាងលើនេះ។
- ក្នុងករណីប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ សោហ៊ុយធ្វើដំណើរត្រូវផ្តល់ជូនតាមតម្លៃសំបុត្ររថយន្តក្រុង រថយន្តឈ្នួល កាណូត ឬកប៉ាល់ ដែលធ្វើដំណើរតាមគោលដៅនៃការបំពេញបេសកកម្ម តាមចំនួនទឹកប្រាក់កត់ត្រាក្នុងវិក្កយបត្រ ឬឯកសារមានលក្ខណៈជាផ្លូវការ។ ការជ្រើសរើសមធ្យោបាយធ្វើដំណើរប្រភេទនេះ ត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមចំនួន ២០ ០០០(ពីរម៉ឺន)រៀល ក្នុង១នាក់ ដើម្បីសម្រួលការធ្វើដំណើរបន្តទៅកាន់គោលដៅបេសកកម្ម។
- ក្នុងករណីមិនអាចប្រើប្រាស់មធ្យោបាយធ្វើដំណើរទាំងពីរប្រភេទខាងលើ ការជួលរថយន្ត ឬជួលមធ្យោបាយធ្វើដំណើរសមស្រប សម្រាប់ការបំពេញបេសកកម្មដូចជា ការធ្វើអធិការកិច្ច សវនកម្ម ការសិក្សាស្រាវជ្រាវ ការត្រួតពិនិត្យការដ្ឋានសំណង់នានា ឬការចុះទៅកាន់តំបន់គោលដៅដាច់ស្រយាល រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវអនុលោមតាមលក្ខខណ្ឌ ដូចខាងក្រោម÷

- រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ត្រូវស្នើសុំគោលការណ៍ជាមុនពីមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត
- រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ត្រូវស្នើសុំការអនុម័តយល់ព្រមជាមុនពីក្រុមប្រឹក្សាសាមី។

**ប្រការ៥._**

ក្នុងករណីប្រើប្រាស់មធ្យោបាយធ្វើដំណើររបស់រដ្ឋ ឬផ្ទាល់ខ្លួន សោហ៊ុយធ្វើដំណើរដូចមានចែងក្នុងប្រការ៤ ខាងលើ ត្រូវផ្តល់ជូន ដូចខាងក្រោម÷

- សម្រាប់មធ្យោបាយធ្វើដំណើរជារថយន្ត គឺរថយន្ត ១ គ្រឿង សម្រាប់បេសកកម្មដែលមានសមាជិកអតិបរមាចំនួន ៤នាក់។ ក្នុងករណីសំណល់នៃផលចែករវាងចំនួនអ្នកធ្វើដំណើរសរុបធៀបនឹងឯកតា (ចំនួន ៤នាក់/រថយន្ត ១ គ្រឿង) មានចំនួនពី ១នាក់ដល់ ៣នាក់ សោហ៊ុយធ្វើដំណើរ ត្រូវផ្តល់ជូនបន្ថែមដោយគិតស្មើនឹងមធ្យោបាយធ្វើដំណើរចំនួន ១ គ្រឿងទៀត។
- សម្រាប់មធ្យោបាយធ្វើដំណើរជាទោចក្រយានយន្ត គឺទោចក្រយានយន្ត ១ គ្រឿង សម្រាប់បេសកកម្មដែលមានសមាជិកអតិបរមាចំនួន ២នាក់។ ក្នុងករណីសំណល់នៃផលចែករវាងចំនួនអ្នកធ្វើដំណើរសរុបធៀបនឹងឯកតា (ចំនួន ២នាក់/ទោចក្រយានយន្ត ១ គ្រឿង) មានចំនួន ១នាក់ សោហ៊ុយធ្វើដំណើរត្រូវផ្តល់ជូនបន្ថែមដោយគិតស្មើនឹងមធ្យោបាយធ្វើដំណើរចំនួន ១ គ្រឿងទៀត។

ចំពោះថ្នាក់ដឹកនាំជាប្រធានក្រុមប្រឹក្សារាជធានី ខេត្ត និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត សោហ៊ុយធ្វើដំណើរត្រូវផ្តល់ជូនដោយគិតស្មើនឹងមធ្យោបាយធ្វើដំណើរចំនួន ១ គ្រឿងសម្រាប់ ១នាក់។

**ប្រការ៦._**

ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត អាចធ្វើដំណើរតាមយន្តហោះ ក្នុងករណីចាំបាច់ ចំពោះការបំពេញបេសកកម្មក្នុងប្រទេស ដោយត្រូវផ្តល់ជូនតាមតម្លៃសំបុត្រយន្តហោះជាក់ស្តែង។ សោហ៊ុយធ្វើដំណើរបន្តពីព្រលានយន្តហោះទៅដល់គោលដៅ ត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមចំនួន ៨០ ០០០ (ប្រាំបីម៉ឺន) រៀល ក្នុង ១នាក់។

## ជំពូកទី៣

## វិធាន និងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេស

### ផ្នែកទី១

### វិធាន និងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មក្នុងប្រទេស

**ប្រការ៧._**

ការអនុវត្តចំណាយសម្រាប់បេសកកម្ម អាចអនុវត្តតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន និងតាមនីតិវិធីទូទាត់ត្រង់។

រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានតម្រូវការក្នុងការអនុវត្តចំណាយប្រាក់បេសកកម្ម ត្រូវគ្រោងចំណាយនេះសម្រាប់អនុវត្តតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុនតាមរយៈរដ្ឋទេយ្យករបុរេប្រទាន និងតាមនីតិវិធីទូទាត់ត្រង់ ទៅតាមតម្រូវការជាក់ស្តែង។

ការអនុវត្តនីតិវិធីបើកផ្តល់សាច់ប្រាក់មុនត្រូវអនុលោមតាមយន្តការជុំបង្វិល និងការបំពេញបន្ថែមឡើងវិញ ដោយត្រូវធ្វើឡើងតាមគោលការណ៍ដូចខាងក្រោម ៖

- មុនដំណាច់ខែវិច្ឆិកា មុនឆ្នាំអនុវត្តថវិកា រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ដែលមានតម្រូវការចំណាយត្រូវរៀបចំលិខិតស្នើសុំបើកប្រាក់លើកដំបូងសម្រាប់ចំណាយបេសកកម្មរបស់ខ្លួន ក្នុងកម្រិតទឹកប្រាក់ ១/៤ នៃឥណទានថវិកាបេសកកម្មសម្រាប់អនុវត្តតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន រួចបញ្ជូនមកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដែលជាអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ និងរតនាគាររាជធានី ខេត្ត ដែលជាគណនេយ្យករសាធារណៈ ដោយត្រូវភ្ជាប់នូវសំណើ ដើម្បីពិនិត្យនិងបើកផ្តល់សាច់ប្រាក់។ ដោយឡែក រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ត្រូវបញ្ជូនត្រង់មកគណនេយ្យករសាធារណៈតែម្តង។ គំរូលិខិតស្នើសុំបើកប្រាក់មានភ្ជាប់ជាឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។
- នៅពេលទទួលបានសំណើសុំបើកសាច់ប្រាក់ អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវពិនិត្យមើលភាពត្រឹមត្រូវនៃសំណើសុំ និងភាពទំនេរនៃឥណទានថវិកា។ ក្នុងករណីមិនយល់ទាស់ទេ អ្នកត្រួតពិនិត្យហិរញ្ញវត្ថុត្រូវរៀបចំផ្តល់យោបល់លើកំណត់បង្ហាញ រួចបញ្ជូនទៅគណនេយ្យករសាធារណៈ ដើម្បីពិនិត្យ និងបើកផ្តល់សាច់ប្រាក់។ ដោយឡែក រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ត្រូវបញ្ជូនត្រង់មកគណនេយ្យករសាធារណៈដើម្បីពិនិត្យ និងបើកផ្តល់សាច់ប្រាក់។
- គណនេយ្យករសាធារណៈ ត្រូវពិនិត្យនិងរៀបចំបើកប្រាក់សម្រាប់ចំណាយបេសកកម្មជូនរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ក្រោយពីទទួលបានសំណើសុំសាច់ប្រាក់ ដែលមិនមានការយល់ទាស់ និងមានអនុលោមភាពត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុរបស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត។ ដោយឡែក រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ គណនេយ្យករសាធារណៈ ត្រូវពិនិត្យនិងរៀបចំបើកប្រាក់សម្រាប់ចំណាយបេសកកម្មជូន ក្រោយពីទទួលបានសំណើសុំសាច់ប្រាក់ ដែលមានអនុលោមភាពត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុ។
- រដ្ឋទេយ្យករបុរេប្រទាន អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ និងគណនេយ្យករសាធារណៈ ត្រូវរក្សាទុកឥណទានថវិកាដែលអនុវត្តតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុនជាបណ្តោះអាសន្ន ក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាថាមានឥណទានថវិកាគ្រប់គ្រាន់សម្រាប់ទូទាត់ជម្រះបញ្ជីលើសាច់ប្រាក់ដែលបានបើកផ្តល់មុន និងមានមូលដ្ឋានតាមដានការប្រើប្រាស់ឥណទានថវិកាបានច្បាស់លាស់ ដោយចំណាយតាមនីតិវិធីទូទាត់ត្រង់ មិនប្រើប្រាស់ឥណទានថវិកាដែលអនុវត្តតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន

ដោយពុំមានការអនុញ្ញាតនោះទេ។

- រដ្ឋលេខាធិការ... 

ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ត្រូវបញ្ជូនត្រង់មកគណនេយ្យករសាធារណៈ ដើម្បីពិនិត្យទូទាត់តែម្តង។

- ក្នុងករណីពិនិត្យឃើញថា អាណត្តិនិយ័តកម្ម និងរបាយការណ៍ចំណាយ ពុំទាន់មានលក្ខណៈត្រឹមត្រូវ និងមិនអនុលោមតាមបទប្បញ្ញត្តិផ្សេងៗនៃប្រកាសនេះ អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ និងគណនេយ្យករសាធារណៈមានសិទ្ធិស្នើសុំការបញ្ជាក់បំភ្លឺពីអាណាប័ក ឬផ្តល់ឯកសារបន្ថែម ឬមិនធ្វើការទូទាត់ជូន។ ក្នុងករណីដែលអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ និង/ឬ គណនេយ្យករសាធារណៈបដិសេធមិនធ្វើការទូទាត់ជូន ដោយសារពុំបានទទួលការបញ្ជាក់ ឬឯកសារបន្ថែមត្រឹមត្រូវ និងគ្រប់គ្រាន់ពីអាណាប័ក អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ និង/ឬ គណនេយ្យករសាធារណៈ ត្រូវបញ្ជូនអាណត្តិនិយ័តកម្មនោះ ត្រលប់ទៅអាណាប័កវិញ ដោយមានការបញ្ជាក់អំពីចំណុចខ្វះខាត។ ក្រោយពីកែតម្រូវលើអាណត្តិនិយ័តកម្ម ឬ លិខិតយុត្តិការចំណាយរួច អាណាប័កត្រូវផ្ញើជូនអ្នកត្រួតពិនិត្យហិរញ្ញវត្ថុសាជាថ្មី ដើម្បីពិនិត្យនិងបញ្ជូនបន្តមកគណនេយ្យករសាធារណៈ។ ដោយឡែក រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ត្រូវបញ្ជូនត្រង់មកគណនេយ្យករសាធារណៈតែម្តង។
- ការបើកផ្តល់ប្រាក់សម្រាប់បេសកកម្មក្នុងប្រទេសបន្ទាប់ទៀត ត្រូវធ្វើឡើងក្រោមរូបភាពជាការបំពេញឡើងវិញនូវប្រាក់ដែលបានចំណាយជាក់ស្តែងដែលជាឧបសម្ពន្ធទី៣ នៃប្រកាសនេះ ទៅតាមទំហំទឹកប្រាក់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិ បានបោះផ្សាយអាណត្តិនិយ័តកម្មស្នើសុំទូទាត់ លើកលែងតែពេលជិតដំណាច់ឆ្នាំ ដែលត្រូវទូទាត់ជម្រះបញ្ជី ដោយផ្អែកតាមសារាចរណែនាំស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកាប្រចាំឆ្នាំ។
- សរុបទឹកប្រាក់ដែលបានទូទាត់ និងដែលត្រូវទូទាត់ជម្រះចំណាយបេសកកម្ម ត្រូវមានទំហំមិនឱ្យលើសពីឥណទានថវិកាសរុបប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគណនី ៦១១២ (សោហ៊ុយបេសកកម្មក្នុងប្រទេស)។
- រដ្ឋបាលថ្នាក់ក្រោមជាតិ មិនត្រូវរក្សាទុកសាច់ប្រាក់ចុងឆ្នាំសម្រាប់ចំណាយនៅឆ្នាំបន្ទាប់ឡើយ។ ក្នុងករណីមានសាច់ប្រាក់នៅសល់ចុងឆ្នាំ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបង់ចូលគណនីចរន្តរបស់រតនាគាររាជធានី ខេត្ត នៅធនាគារពាណិជ្ជដៃគូ ឱ្យបានមុនដំណាច់ឆ្នាំថវិកានីមួយៗ ដោយត្រូវរៀបចំសំណើបង់សាច់ប្រាក់សល់ពីការបើកផ្តល់មុន ដោយបញ្ជាក់ខ្លឹមសារឱ្យច្បាស់លាស់អំពីការទូទាត់ជម្រះប្រាក់បេសកកម្ម និងភ្ជាប់មកជាមួយនូវប្រកាសឥណទាន ឬ ប័ណ្ណបង់ប្រាក់ ឬ របាយការណ៍ធនាគារ។ ក្នុងករណីមិនទាន់មានការបង់សាច់ប្រាក់នៅសល់ និងមិនទាន់មានការបោះផ្សាយអាណត្តិនិយ័តកម្មទូទាត់ឱ្យទាន់នាដំណាច់ឆ្នាំអនុវត្តថវិកា រតនាគាររាជធានី ខេត្ត នឹងមិនបើកផ្តល់សាច់ប្រាក់បេសកកម្មសម្រាប់ឆ្នាំបន្ទាប់ ជូនរដ្ឋបាលថ្នាក់ក្រោមជាតិនោះទេ។

ក្នុងករណី ការអនុវត្តចំណាយប្រព្រឹត្តទៅមុនពេលទទួលបានប្រាក់ពីគណនេយ្យករសាធារណៈ អាណាប័កត្រូវធានាថា មានឥណទានថវិកាគ្រប់គ្រាន់ និងស្របតាមគោលរបបដែលមានចែងក្នុងអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងប្រកាសនេះ ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម÷

- រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ អាចបោះផ្សាយអាណត្តិបើកប្រាក់តែម្តង បញ្ជូនមកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត និងរតនាគាររាជធានី ខេត្ត។
- រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ អាចបោះផ្សាយអាណត្តិបើកប្រាក់តែម្តង បញ្ជូនត្រង់មករតនាគាររាជធានី ខេត្ត។

**ប្រការ៨._**

រដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរង ត្រូវទទួលខុសត្រូវ ផ្នែករដ្ឋបាល ផ្នែករដ្ឋប្បវេណី ផ្នែកព្រហ្មទណ្ឌ និងផ្នែកប្រាក់កាស ចំពោះការទុកដាក់ថែរក្សានូវសាច់ប្រាក់បេសកកម្មដែលខ្លួនបានទទួល ឬ បានចំណាយនេះ ការទុកដាក់ថែរក្សាលិខិតយុត្តិការ និងការកាន់កាប់បញ្ជីគណនេយ្យនៃកិច្ចប្រតិបត្តិការ។

**ប្រការ៩._**

ប្រាក់បេសកកម្ម ត្រូវផ្តល់ជូនសមាសភាពក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ មន្ត្រីរាជការសាធារណៈគ្រប់លំដាប់ថ្នាក់ មន្ត្រីជាប់កិច្ចសន្យាដែលមានការទទួលស្គាល់ជាផ្លូវការពីក្រសួងមុខងារសាធារណៈ ដែលបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់ ដោយមានបម្លាស់ទីចេញពីក្នុងរង្វង់ដែនដីនៃរាជធានី ឬរង្វង់ដែនដីនៃឃុំ/សង្កាត់ នៃក្រុង/ស្រុក ដែលសាមីខ្លួនបំពេញមុខងារជាប្រក្រតី តាមលក្ខខណ្ឌកំណត់ដូចខាងក្រោម÷

- ផ្តល់ជូនប្រាក់ហោប៉ៅ សម្រាប់ការបម្លាស់ទីដែលមានចម្ងាយក្រោម ២០(ម្ភៃ) គីឡូម៉ែត្រ។
- ផ្តល់ជូនប្រាក់ហោប៉ៅ ប្រាក់ហូបចុក និងសោហ៊ុយធ្វើដំណើរ សម្រាប់ការបម្លាស់ទីដែលមានចម្ងាយចាប់ពី ២០(ម្ភៃ) គីឡូម៉ែត្រឡើង។
- ផ្តល់ជូនបន្ថែម នូវប្រាក់ស្នាក់នៅ សម្រាប់ការបម្លាស់ទីដែលមានចម្ងាយលើសពី ៤០(សែសិប) គីឡូម៉ែត្រ និងបេសកកម្មតម្រូវឱ្យមានការសម្រាកនៅពេលយប់ តាមការសម្រេចរបស់អាណាប័ក។

**ប្រការ១០._**

ក្នុងករណីរដ្ឋបាលថ្នាក់ក្រោមជាតិ មានតម្រូវការបំពេញបេសកកម្មក្នុងប្រទេស លើសពីចំនួនកំណត់ ១០ថ្ងៃ ក្នុងមួយខែ ដោយធានាថាគម្រោងចំណាយ ដែលបានស្នើពិតជាត្រឹមត្រូវទៅតាមប្រភេទថវិកា និងឥណទានទំនេរ ដែលមាននៅក្នុងសៀវភៅថវិកា រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវអនុលោមតាមគោលការណ៍ ដូចខាងក្រោម÷

- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងខណ្ឌ ក្នុងនាមរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ត្រូវស្នើសុំគោលការណ៍ចំណាយមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីពិនិត្យពីភាពត្រឹមត្រូវនៃកម្មវត្ថុចំណាយ ភាពទំនេរនៃឥណទាន ការកត់ត្រាចំណាយ និងផ្តល់ទិដ្ឋាការធានាចំណាយ មុននឹងធ្វើការបើកផ្តល់ប្រាក់បេសកកម្ម។
- អភិបាលនៃគណៈអភិបាលក្រុង ស្រុក និងមេឃុំ ចៅសង្កាត់ ក្នុងនាមរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ត្រូវស្នើសុំការអនុម័តយល់ព្រមជាមុនពីក្រុមប្រឹក្សាសាមី លើសំណើបេសកកម្មលើសពីចំនួនថ្ងៃកំណត់។ ឯកសារលិខិតយុត្តិការ និងកំណត់ហេតុនៃអង្គប្រជុំពិភាក្សា និងអនុម័តយល់ព្រមរបស់ក្រុមប្រឹក្សា នឹងក្លាយជាកម្មវត្ថុនៃការពិនិត្យរបស់រតនាគាររាជធានី ខេត្ត នៅពេលដែលរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ អនុវត្តនីតិវិធីទូទាត់ប្រាក់បេសកកម្ម។

**ប្រការ១១._**

មុខសញ្ញាចំណាយដែលមានរបបកំណត់ដូចមានចែងក្នុងមាត្រា៧ និងមាត្រា៨ នៃអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ មិនតម្រូវឱ្យមានវិក្កយបត្រទេ ប៉ុន្តែតម្រូវឱ្យភ្ជាប់នូវលិខិតបញ្ជាបេសកកម្ម និងទិដ្ឋាការធ្វើដំណើរដែលមានការបញ្ជាក់ពីអង្គភាពគោលដៅបេសកកម្ម ដែលជាមូលដ្ឋានអត្ថិភាពនៃចំណាយបេសកកម្ម។ ដោយឡែក ការទូទាត់សោហ៊ុយធ្វើដំណើរដោយមិនប្រើប្រាស់មធ្យោបាយធ្វើដំណើររបស់រដ្ឋ ឬ ផ្ទាល់ខ្លួន និងចំណាយផ្សេងៗ តម្រូវឱ្យមានវិក្កយបត្រស្របតាមនីតិវិធីហិរញ្ញវត្ថុ។

រាល់ការទូទាត់ចំណាយបេសកកម្មក្នុងប្រទេសត្រូវគិតជាប្រាក់រៀល។

## ផ្នែកទី២

## វិធាននិងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មក្រៅប្រទេស

**ប្រការ១២._**

ការកំណត់តំបន់និងក្រុមប្រទេសតាមតំបន់ សម្រាប់ចំណាយបេសកកម្មក្រៅប្រទេស ត្រូវអនុវត្តតាមតារាងភូមិសាស្ត្រ ស្តីពីឈ្មោះប្រទេសនិងរាជធានី ឬ រដ្ឋធានី ដែលជាឧបសម្ពន្ធទី៤ នៃប្រកាសនេះ។

**ប្រការ១៣._**

ក្នុងករណីមានបេសកកម្មក្រៅប្រទេស រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវអនុវត្តតាមវិធាន និងនីតិវិធីដូចខាងក្រោម÷

- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងខណ្ឌ ក្នុងនាមរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ត្រូវស្នើសុំទិដ្ឋាការធានាចំណាយជាមុនពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយមានឯកសារពាក់ព័ន្ធគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីភាពចាំបាច់នៃបេសកកម្ម។ ប្រាក់បេសកកម្ម ដែលបានទទួលទិដ្ឋាការធានាចំណាយពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត

រួច អាណាប័កអាចបោះផ្សាយអាណត្តិបើកប្រាក់ជារបបកំណត់ផ្តល់ជូនតែម្តង។ ក្រោយពេលត្រលប់មកវិញ អ្នកចុះបេសកកម្មត្រូវបំពេញ និងផ្តល់ឯកសារលិខិតយុត្តិការគ្រប់គ្រាន់ និងត្រឹមត្រូវសម្រាប់ទូទាត់ជម្រះចំណាយតាមការជាក់ស្តែង។

- អភិបាលនៃគណៈអភិបាលក្រុង ស្រុក និងមេឃុំ ចៅសង្កាត់ ក្នុងនាមរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ត្រូវស្នើសុំការអនុម័តយល់ព្រមជាមុនពីក្រុមប្រឹក្សាសាមី លើសំណើបេសកកម្មក្រៅប្រទេស។ អាណាប័ក អាចបោះផ្សាយអាណត្តិបើកប្រាក់ជារបបកំណត់សម្រាប់ផ្តល់ជូនតែម្តង ហើយបញ្ជូនត្រង់មករតនាគាររាជធានី ខេត្ត ដោយភ្ជាប់ជាមួយកំណត់ហេតុនៃអង្គប្រជុំពិភាក្សានិងអនុម័តយល់ព្រមរបស់ក្រុមប្រឹក្សា។ ក្រោយពេលត្រលប់មកវិញ អ្នកចុះបេសកកម្មត្រូវបំពេញ និងផ្តល់ឯកសារលិខិតយុត្តិការគ្រប់គ្រាន់និងត្រឹមត្រូវសម្រាប់ជម្រះចំណាយតាមការជាក់ស្តែង។

**ប្រការ១៤._**

ការបំពេញបេសកកម្មទៅប្រទេសអាស៊ាន មិនតម្រូវឱ្យមានការស្នើសុំធានាចំណាយជាមុនពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្តទេ។ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបោះផ្សាយអាណត្តិបើកប្រាក់មុនពេលបំពេញបេសកកម្ម ហើយសម្រាប់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ត្រូវបញ្ជូនមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្តរីឯរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ត្រូវបញ្ជូនត្រង់មករតនាគាររាជធានីខេត្តតែម្តង ដោយអនុវត្តតាមគោលរបបកំណត់សម្រាប់ប្រាក់ហោប៉ៅ ប្រាក់ហូបចុក និងស្នាក់នៅ ដូចមានចែងក្នុងមាត្រា១៣ នៃអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ដោយឡែក តម្លៃសំបុត្រយន្តហោះត្រូវផ្អែកតាមតារាងថ្លៃដែលរៀបចំ និងធ្វើបច្ចុប្បន្នភាពដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានគោលនយោបាយ) ដោយប្រើប្រាស់ជើងហោះហើរដែលមានលក្ខណៈសន្សំសំចៃបំផុត។

**ប្រការ១៥._**

នីតិវិធីចំណាយប្រាក់បេសកកម្មក្រៅប្រទេសក្រៅពីប្រទេសអាស៊ាន ត្រូវអនុវត្តតាមខ្លឹមសារនៃមាត្រា១៩ មាត្រា២០ មាត្រា២១ និងមាត្រា២២ នៃអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងនីតិវិធី ដូចខាងក្រោម÷

- រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការសកម្មភាពសម្រាប់បំពេញបេសកកម្ម ដោយត្រូវរៀបចំគម្រោងចំណាយឱ្យបានពីចម្ងាយ សម្រាប់រៀបចំនីតិវិធីស្នើសុំគោលការណ៍ធានាចំណាយ និងរៀបចំបោះផ្សាយអាណត្តិបើកប្រាក់។
- ក្នុងករណីរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ បោះផ្សាយអាណត្តិបើកប្រាក់ ដោយមិនបានសុំទិដ្ឋាការធានាចំណាយជាមុន មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត មាននីត្យានុកូលភាព

គ្រប់គ្រាន់ក្នុងការត្រួតពិនិត្យ កាត់ចេញចំណែកខ្លះនៃចំណាយ ឬបដិសេធទាំងស្រុងជាយថាហេតុ នូវចំណាយថវិកាដែលមិនត្រឹមត្រូវតាមគោលការណ៍និងនីតិវិធីហិរញ្ញវត្ថុ និងបញ្ជូនអាណត្តិដែលបានបោះផ្សាយរួចត្រលប់ទៅរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ដើម្បីរៀបចំការបោះផ្សាយអាណត្តិបើកប្រាក់សាជាថ្មីឡើងវិញ ឬលុបចោលទាំងស្រុង។ អាណាប័ក ត្រូវទទួលខុសត្រូវទាំងស្រុងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ក្នុងករណីអនុញ្ញាតឱ្យអនុវត្តចំណាយបេសកកម្មទៅក្រៅប្រទេសដែលគ្មានការអនុញ្ញាតជាមុនពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត។

- ចំណាយបេសកកម្មដែលបានទទួលទិដ្ឋាការធានាចំណាយពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្តរួចហើយ អាណាប័កអាចបោះផ្សាយអាណត្តិបើកប្រាក់ជារបបកំណត់សម្រាប់ផ្តល់ជូនតែម្តង។ ក្រោយពេលត្រលប់មកវិញ អ្នកចុះបេសកកម្មត្រូវបំពេញឯកសារលិខិតយុត្តិការគ្រប់គ្រាន់និងត្រឹមត្រូវសម្រាប់ទូទាត់ជម្រះចំណាយតាមការជាក់ស្តែង។
- រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ អាចបោះផ្សាយអាណត្តិបើកប្រាក់បញ្ជូនត្រង់មករតនាគាររាជធានី ខេត្តតែម្តង។ រតនាគាររាជធានី ខេត្ត មាននីត្យានុកូលភាពគ្រប់គ្រាន់ក្នុងការបដិសេធទាំងស្រុងជាយថាហេតុ នូវចំណាយថវិកាដែលមិនត្រឹមត្រូវតាមគោលការណ៍និងនីតិវិធីហិរញ្ញវត្ថុ និងបញ្ជូនអាណត្តិដែលបានបោះផ្សាយរួចត្រលប់ទៅរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ដើម្បីរៀបចំការបោះផ្សាយអាណត្តិបើកប្រាក់សាជាថ្មីឡើងវិញ ឬលុបចោលទាំងស្រុង។ អាណាប័ក ត្រូវទទួលខុសត្រូវទាំងស្រុងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ក្នុងករណីអនុញ្ញាតឱ្យអនុវត្តចំណាយបេសកកម្មទៅក្រៅប្រទេសដែលគ្មានការអនុម័តយល់ព្រមជាមុនពីក្រុមប្រឹក្សា។ ក្រោយពេលត្រលប់មកវិញ អ្នកចុះបេសកកម្មត្រូវបំពេញឯកសារលិខិតយុត្តិការគ្រប់គ្រាន់និងត្រឹមត្រូវសម្រាប់ទូទាត់ជម្រះចំណាយតាមការជាក់ស្តែង។

**ប្រការ១៦._**

ក្នុងករណីមានការពន្យារពេលបំពេញបេសកកម្មដោយមូលហេតុសត្យានុម័ត ប្រាក់បេសកកម្មអាចត្រូវបានផ្តល់ជូនបន្ថែម តាមលក្ខខណ្ឌដូចខាងក្រោម÷

- ត្រូវមានការយល់ព្រមពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត សម្រាប់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ
- ត្រូវមានការអនុម័តយល់ព្រមពីក្រុមប្រឹក្សា សម្រាប់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់
- អាណាប័ក ត្រូវទទួលខុសត្រូវលើភាពត្រឹមត្រូវនៃលិខិតយុត្តិការចំណាយរបស់គណៈប្រតិភូរួមទាំងរបាយការណ៍សម្រាប់ជាមូលដ្ឋាននៃការទូទាត់បន្ថែមនេះ។

**ប្រការ១៧._**

មុខចំណាយសម្រាប់បេសកកម្មក្រៅប្រទេស ត្រូវបានផ្តល់តាមគោលការណ៍ដូចខាងក្រោម÷

- ប្រាក់បេសកកម្មអាចត្រូវបានអនុញ្ញាតឱ្យគ្រោងបន្ថែមចំនួនពីរថ្ងៃគឺ មុនមួយថ្ងៃ និងក្រោយមួយថ្ងៃនៃកម្មវិធីផ្លូវការ។ ករណីដែលជើងហោះហើរត្រូវចេញដំណើរ និងត្រលប់មកវិញលើសពីពីរថ្ងៃ ត្រូវតែមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់។
- ការធ្វើដំណើរលើយន្តហោះពេលយប់ដែលមិនមានតម្រូវការស្នាក់នៅ នោះសោហ៊ុយស្នាក់នៅមិនត្រូវបានផ្តល់ជូនឡើយ។
- សម្រាប់ថ្ងៃបេសកកម្មដែលចេញដំណើរក្រោយម៉ោង ២០:០០នាទី និងត្រលប់មកដល់វិញមុនម៉ោង ៧:០០នាទីព្រឹក ផ្តល់ជូនតែប្រាក់ហោប៉ៅ ប៉ុន្តែប្រាក់ហូបចុកមិនត្រូវបានផ្តល់ជូនឡើយ។
- មុខចំណាយទាំងឡាយណាដែលត្រូវបានទទួលរ៉ាប់រងពីភាគីអញ្ជើញ មិនត្រូវបានផ្តល់ជូនឡើយ។ ក្នុងករណីដែលរាល់មុខចំណាយទាំងអស់ជាបន្ទុកទាំងស្រុងរបស់ភាគីអញ្ជើញ មានតែប្រាក់ហោប៉ៅប៉ុណ្ណោះ ដែលត្រូវផ្តល់ជូនជាប្រាក់បេសកកម្ម និងមានកម្រិតមិនឱ្យលើសពី ១០(ដប់)ថ្ងៃ។

**ប្រការ១៨._**

សោហ៊ុយធ្វើដំណើរក្នុងស្រុកនៃប្រទេសគោលដៅបេសកកម្ម ត្រូវផ្តល់ជូនក្នុងករណីមានតម្រូវការចាំបាច់ជាក់ស្តែងប៉ុណ្ណោះ ដោយកំណត់កម្រិតអតិបរមា ដូចខាងក្រោម ÷

- ចំនួន ១០០(មួយរយ) ដុល្លារអាម៉េរិក សម្រាប់ប្រតិភូមានសមាជិកចំនួន ១នាក់
- ចំនួន ១៥០(មួយរយហាសិប) ដុល្លារអាម៉េរិក សម្រាប់ប្រតិភូមានសមាជិកចំនួន ២នាក់
- ចំនួន ៥០ (ហាសិប) ដុល្លារអាម៉េរិក/១នាក់ សម្រាប់ប្រតិភូមានសមាជិកលើសពីចំនួន ២នាក់។

**ប្រការ១៩._**

ប្រាក់ចំណាយលើវត្ថុអនុស្សាវរីយ៍ត្រូវផ្តល់ជូនចំពោះបេសកកម្មដែលដឹកនាំដោយប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ឬ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬ តំណាងដែលជាប្រធានប្រតិភូ ដើម្បីចូលរួមកិច្ចចរចាទ្វេរភាគី ឬ ពហុភាគីតាមការប្រគល់សិទ្ធិរបស់រាជរដ្ឋាភិបាល។

ប្រាក់ចំណាយផ្សេងៗ ត្រូវផ្តល់ជូនក្នុងកម្រិតមួយសមស្រប និងតាមករណីចាំបាច់ ដោយផ្អែកលើគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលស្នើសុំចំណាយ។

**ប្រការ២០._**

ការទូទាត់ចំណាយបេសកកម្មទៅក្រៅប្រទេស តម្រូវឱ្យមានវិក្កយបត្រ ចំពោះសោហ៊ុយធ្វើដំណើរ ចំណាយវត្ថុអនុស្សាវរីយ៍ និងចំណាយផ្សេងៗប៉ុណ្ណោះ។ ចំពោះរាល់មុខចំណាយដែលអត្រាកំណត់ដូចមានចែងក្នុងមាត្រា១៣ នៃអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្តីពីប្រាក់បេសកកម្មក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ មិនតម្រូវឱ្យមានវិក្កយបត្រទេ។

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្តល់នូវលិខិតយុត្តិការចំណាយផ្សេងៗ ដូចជា ប័ណ្ណឡើងជិះយន្តហោះ ឯកសារចម្លងនៃលិខិតឆ្លងដែនដែលមានបោះត្រាចេញ-ចូលប្រទេសគោលដៅបំពេញបេសកកម្ម ក្រោយពេលបញ្ចប់បេសកកម្មយ៉ាងយូរត្រឹមរយៈពេល៣០ថ្ងៃ មកដល់រតនាគាររាជធានី ខេត្ត ដើម្បីរក្សាទុក។ ចំពោះប្រភេទលិខិតឆ្លងដែនអេឡិចត្រូនិកដែលត្រូវបានស្កេនចេញចូលដោយទ្វារស្វ័យប្រវត្តិ មិនតម្រូវឱ្យមានត្រាចេញ-ចូលលើលិខិតឆ្លងដែនទេ ប៉ុន្តែត្រូវមានប័ណ្ណឡើងជិះយន្តហោះ ឬ ឯកសារបញ្ជាក់អំពីការបំពេញបេសកកម្ម។

**ប្រការ២១._**

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវសន្សំសំចៃឥណទានថវិកាសម្រាប់ចំណាយប្រាក់បេសកកម្មទៅក្រៅប្រទេស ដោយត្រូវ ៖

- ប្រើប្រាស់ជើងហោះហើរដែលមានលក្ខណៈសន្សំសំចៃបំផុត
- កាត់បន្ថយសមាជិកឱ្យនៅចំនួនតិចបំផុត
- ស្នើសុំគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល ដើម្បីឱ្យស្ថានទូត ឬស្ថានកុងស៊ុលកម្ពុជាប្រចាំប្រទេសនោះចូលរួមជំនួស
- កក់សំបុត្រយន្តហោះឱ្យបានមុនពីចម្ងាយដើម្បីទទួលបានតម្លៃសំបុត្រថោកជាង និងគួរទិញសំបុត្រយន្តហោះពីក្រុមហ៊ុន ឬភ្នាក់ងារទេសចរណ៍ដែលមានការចុះបញ្ជីត្រឹមត្រូវ មានកេរ្តិ៍ឈ្មោះ និងស្នាដៃល្អ និងក្នុងតម្លៃប្រកួតប្រជែង (តម្លៃសមរម្យ) រយៈពេលបេសកកម្មត្រូវកម្រិតខ្ពស់បំផុតត្រឹម ១០ (ដប់)ថ្ងៃក្នុងមួយខែ។

**ប្រការ២២._**

អ្នកបំពេញបេសកកម្មត្រូវជ្រើសរើសជើងហោះហើរដែលមានលក្ខណៈសន្សំសំចៃបំផុត។ ក្នុងករណីសាមីខ្លួនជ្រើសរើសជើងហោះហើរឆ្លងកាត់ព្រលានយន្តហោះដែលត្រូវរង់ចាំដើម្បីចំណាយពេលសម្រាប់កិច្ចការឯកជន សាមីខ្លួនត្រូវទទួលខុសត្រូវចំពោះចំណាយបន្ថែមទៅលើមធ្យោបាយធ្វើដំណើរ និងត្រូវទទួលខុសត្រូវចំពោះការប៉ះពាល់ដល់កម្មវិធីបំពេញបេសកកម្ម ឬឧបទ្ទវហេតុកើតឡើងជាយថាហេតុ។

**ប្រការ២៣._**

រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានតម្រូវការបំពេញបេសកកម្មក្រៅប្រទេសលើសពីចំនួនកំណត់ ១០ថ្ងៃ ក្នុងមួយខែ ត្រូវរៀបចំផែនការបេសកកម្មក្រៅប្រទេសដែលលើសចំនួនថ្ងៃកំណត់សម្រាប់ឆ្នាំថវិកានីមួយៗ ដោយត្រូវបញ្ជាក់ទន្នីករណ៍ដែលជាមូលហេតុនៃបេសកកម្មលើសពី ១០ថ្ងៃ ក្នុងមួយខែ និងចំណាយលម្អិតរួចផ្ញើមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ពិនិត្យ និងអនុម័តជាមុន សម្រាប់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ។ ដោយឡែក រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ត្រូវមានការអនុម័តយល់ព្រមជាមុនពីក្រុមប្រឹក្សាសាមី។

ក្នុងករណីបេសកកម្មលើសពី ១០ថ្ងៃ ក្នុងមួយខែដែលពុំបានគ្រោងទុក រដ្ឋបាលរាជធានី ខេត្ត និង រដ្ឋបាលខណ្ឌ ត្រូវស្នើសុំជាមុនមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត នូវគោលការណ៍អនុញ្ញាត ដោយឡែកតាមករណីជាក់ស្តែងនីមួយៗ។ ដោយឡែក រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ត្រូវ មានការអនុម័តយល់ព្រមជាមុនពីក្រុមប្រឹក្សារបស់ខ្លួន។

**ប្រការ២៤._**

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើវិចារណកម្មលើចំណាយប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេស ដោយកាត់បន្ថយជាអតិបរមានូវចំនួនបេសកកម្ម និងចំនួនថ្ងៃបេសកកម្មមិនចាំបាច់ ឬ កម្រិតចំនួនមន្ត្រី បំពេញបេសកកម្ម អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**ប្រការ២៥._**

រាល់បេសកកម្មនៅក្នុង និងក្រៅប្រទេសដែលបានអនុវត្តនៅក្នុងត្រីមាសទី ៤ នៃឆ្នាំមុន មិនទាន់ ទូទាត់ត្រូវបានអនុញ្ញាតឱ្យទូទាត់ក្នុងរយៈពេលយ៉ាងយូរបំផុតត្រឹមត្រីមាសទីមួយនៃឆ្នាំបន្ទាប់ ដោយអនុវត្ត នីតិវិធីទូទាត់ត្រង់ និងប្រើឥណទានថវិកានៅឆ្នាំបន្ទាប់។ ហួសកាលកំណត់នេះ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី ខេត្ត ឬ រតនាគាររាជធានី ខេត្ត មាននីត្យានុកូលភាពគ្រប់គ្រាន់ក្នុងការបដិសេធការទូទាត់ប្រាក់ បេសកកម្ម លើកលែងតែមានការពន្យល់ច្បាស់លាស់ពីមូលហេតុនៃការយឺតយ៉ាវ ។

រាល់បេសកកម្មនៅក្នុង និងក្រៅប្រទេសដែលបានអនុវត្តនៅក្នុងបីត្រីមាសដំបូងនៃឆ្នាំមុន និងបណ្តា ឆ្នាំកន្លងទៅ មិនត្រូវបានអនុញ្ញាតឱ្យទូទាត់នៅឆ្នាំបន្ទាប់ឡើយ។

## ជំពូកទី៤

## បទប្បញ្ញត្តិសម្រាប់បេសកកម្មនៅតាមតំបន់ជាប់ព្រំដែន

**ប្រការ២៦._**

បេសកកម្មនៅតាមតំបន់ជាប់ព្រំដែន គឺការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមាន បម្លាស់ទីចេញពីក្នុងរង្វង់ដែនដីនៃឃុំ/សង្កាត់ នៃក្រុង/ស្រុក ដែលសាមីខ្លួនបំពេញការងារជាប្រក្រតី ចូលក្នុង ដែនដីនៃប្រទេសថៃ ប្រទេសឡាវ ឬ ប្រទេសវៀតណាម ក្នុងចម្ងាយមិនលើសពី ២០(ម្ភៃ) គីឡូម៉ែត្រ គិតពី ព្រំដែននៃព្រះរាជាណាចក្រកម្ពុជា។

វិធាននិងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅតាមតំបន់ជាប់ព្រំដែន ក្នុងចម្ងាយផ្លូវដូចវាក្យខណ្ឌ ខាងលើ ត្រូវអនុលោមតាមគោលការណ៍ និងគោលរបប ដូចមានចែងក្នុងជំពូកទី២ ប្រាក់បេសកកម្មនៅ ក្នុងប្រទេស នៃអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្តីពីប្រាក់បេសកកម្ម នៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

## ជំពូកទី៥

## បទប្បញ្ញត្តិដោយឡែក

**ប្រការ២៧._**

ប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេស ត្រូវបានផ្តល់ជូនថ្នាក់ដឹកនាំនិងបុគ្គលិក នៃការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយត្រូវបានកំណត់តាមប្រភេទ ដូចមានចែងក្នុងមាត្រា៦ និងមាត្រា១១ នៃអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដូចខាងក្រោម÷

- **ប្រាក់បេសកកម្មនៅក្នុងប្រទេស**

  **ប្រភេទ ខ២:** ប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត

  **ប្រភេទ គ:** អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត និងប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ

  **ប្រភេទ ឃ:** ប្រធាន អនុប្រធានផ្នែកការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត

  **ប្រភេទ ង:** បុគ្គលិកការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត បុគ្គលិកការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌដែលជ្រើសរើសពីមន្ត្រីរាជការ ស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យាដែលមានការទទួលស្គាល់ជាផ្លូវការពីក្រសួងមុខងារសាធារណៈ។

- **ប្រាក់បេសកកម្មនៅក្រៅប្រទេស**

  **ប្រភេទ ខ:** ប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត

  **ប្រភេទ គ:** អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត និងប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ

  **ប្រភេទ ឃ:** ប្រធាន អនុប្រធានផ្នែកការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត

  **ប្រភេទ ង:** បុគ្គលិកការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត បុគ្គលិកការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌដែលជ្រើសរើសពីមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យាដែលមានការទទួលស្គាល់ជាផ្លូវការពីក្រសួងមុខងារសាធារណៈ។

## ជំពូកទី៦

## ទោសប្បញ្ញត្តិ

**ប្រការ២៨._**

សមាសភាពក្រុមប្រឹក្សា មន្ត្រីរាជការសាធារណៈគ្រប់ប្រភេទ និងគ្រប់ឋានៈ ប្រធាន/អនុប្រធាន/ប្រធានផ្នែក/អនុប្រធានផ្នែក/បុគ្គលិកនៃការិយាល័យប្រជាពលរដ្ឋ និងមន្ត្រីជាប់កិច្ចសន្យា ព្រមទាំងជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់ ត្រូវទទួលទណ្ឌកម្មរដ្ឋបាល និងសំណងរដ្ឋប្បវេណី តាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ចំពោះសកម្មភាពដែលបានប្រព្រឹត្ត ឬសមគំនិតក្នុងការប្រព្រឹត្ត ដូចខាងក្រោម÷

- ការក្លែងបន្លំលិខិតយុត្តិការចំណាយ និងលិខិតស្នាមផ្សេងៗ ក្នុងគោលបំណងទទួលបានប្រាក់បេសកកម្មដែលខ្លួនពុំមានសិទ្ធិទទួលតាមបទប្បញ្ញត្តិជាធរមាន
- ការបង្វែរ ឬកេងប្រវ័ញ្ចប្រាក់បេសកកម្ម ដើម្បីយកទៅប្រើប្រាស់ក្រៅពីការបំពេញបេសកកម្ម
- ការបង្កើនរយៈពេលបំពេញបេសកកម្ម និង/ឬ ចំនួនមន្ត្រីចុះបេសកកម្មដែលខុសពីបេសកកម្មដែលបានអនុវត្តជាក់ស្តែង
- ការបង្កើតបេសកកម្មដោយក្លែងបន្លំ ក្នុងគោលបំណងទទួលបានប្រាក់ឧបត្ថម្ភបន្ថែម
- ការទទួលបានប្រាក់បេសកកម្មតែមិនបានផ្តល់ជូនសាមីមន្ត្រីរាជការសាធារណៈដែលត្រូវបំពេញបេសកកម្ម
- ការរារាំង ឬការព្យាយាមរារាំងដល់ដំណើរការត្រួតពិនិត្យប្រក្រតីភាពនៃការអនុវត្តប្រាក់បេសកកម្ម។

ទណ្ឌកម្មនេះមិនមែនជាឧបសគ្គសម្រាប់ការចោទប្រកាន់ និងការផ្តន្ទាទោសព្រហ្មទណ្ឌស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជាឡើយ។

**ប្រការ២៩._**

អនុលោមតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ទណ្ឌកម្មរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល រួមមានជាអាទិ៍÷

- ការស្តីបន្ទោស
- ការផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ
- ការលុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់
- ការដាក់ឱ្យនៅទំនេរគ្មានបៀវត្ស
- ការបន្ថយឋានន្តរស័ក្តិឬថ្នាក់
- ការដាក់ឱ្យចូលនិវត្តន៍មុនកាលកំណត់
- ការបញ្ឈប់ពីការងារដោយបង្ខំ ឬការបណ្តេញចេញពីមុខតំណែងជាមន្ត្រីរាជការ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**ប្រការ៣០._**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តជំនួសប្រកាសលេខ ៨៣០ សហវ.ប្រក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីវិធាននិងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៣១._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៤ ខែ សីហា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលថ្នាក់ក្រោមជាតិ
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
- រតនាគាររាជធានី ខេត្ត
- ដូចប្រការ៣១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ពន្ធទី៦.១ (សម្រាប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់)**

(ឧបសម្ពន្ធភ្ជាប់ប្រកាសលេខ....................... ចុះថ្ងៃទី....... ខែ.......... ឆ្នាំ......... ស្តីពីវិធាននិងនីតិវិធីចំណាយ

ប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្ត...**

**រដ្ឋបាលក្រុង ស្រុក ខណ្ឌ... /មន្ទីរសុខាភិបាលខេត្ត.../ទីភ្នាក់ងារប្រតិបត្តិការពិសេស...**

**រដ្ឋបាលឃុំ សង្កាត់...**

លេខ÷

ថ្ងៃ ... ... ... ខែ ...... ឆ្នាំ ..... ស័ក ព.ស. ....

រាជធានីភ្នំពេញ/ខេត្ត..., ថ្ងៃទី... ខែ...ឆ្នាំ........

**គោរពជូន**

**លោក លោកស្រី ប្រធានធនាគាររាជធានី ខេត្ត**

**កម្មវត្ថុ÷** សំណើសុំបើកប្រាក់លើកដំបូងសម្រាប់ចំណាយប្រាក់បេសកកម្ម ចំនួន.........................។

**យោង÷** - ប្រកាសលេខ សហវ.ប្រក ចុះថ្ងៃទី ខែ ឆ្នាំ ស្តីពីវិធាននិងនីតិវិធីចំណាយប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

- តារាងឧបសម្ពន្ធគម្រោងចំណាយប្រាក់បេសកកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក......។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោក លោកស្រី** មេត្តាជ្រាបថា÷ ដើម្បីឱ្យកិច្ចដំណើរការទូទាត់ចំណាយប្រាក់បេសកកម្មជូនថ្នាក់ដឹកនាំ និងមន្ត្រី បានទាន់ពេលវេលា និងស្របតាមនីតិវិធីចំណាយ រដ្ឋបាលខេត្ត.../រដ្ឋបាលក្រុង ស្រុក ខណ្ឌ.../មន្ទីរសុខាភិបាលខេត្ត.../ទីភ្នាក់ងារប្រតិបត្តិការពិសេស... / រដ្ឋបាលឃុំ សង្កាត់... ស្នើសុំបើកប្រាក់លើកដំបូងសម្រាប់ចំណាយប្រាក់បេសកកម្មរបស់រដ្ឋបាលរាជធានី ខេត្ត.../រដ្ឋបាលក្រុង ស្រុក ខណ្ឌ.../មន្ទីរសុខាភិបាលខេត្ត.../ទីភ្នាក់ងារប្រតិបត្តិការពិសេស... /រដ្ឋបាល ឃុំ សង្កាត់... ក្នុងកម្រិតទឹកប្រាក់ ១/៤ នៃឥណទានថវិកាសម្រាប់ចំណាយបេសកកម្ម ចំនួន .................. ដោយផ្ទេរចូលគណនីរបស់រដ្ឋទេយ្យករបុរេប្រទានលេខ .......................... នៅធនាគារ......................។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោក លោកស្រី** មេត្តាពិនិត្យ និងសម្រេចបើកផ្តល់តាមការគួរ។

សូម **លោក លោកស្រី** មេត្តាទទួលនូវគោរព ពីខ្ញុំ

**ហត្ថលេខា និងត្រា**

**អាណាប័ក/អាណាប័កផ្ទេរសិទ្ធិ**

**ឧបសម្ព័ន្ធទី១.២ (សម្រាប់រដ្ឋបាលរាជធានី ខេត្ត ខណ្ឌ/ អង្គភាពថវិកា)**

(ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ...................... ចុះថ្ងៃទី...... ខែ......... ឆ្នាំ........ ស្តីពីវិធាននិងនីតិវិធីចំណាយ
ប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានី ខេត្ត ខណ្ឌ៖** .................
**អង្គភាពថវិកា៖**.................

**គម្រោងចំណាយប្រាក់បេសកកម្មតាមចំណាត់ថ្នាក់សេដ្ឋកិច្ចសម្រាប់ឆ្នាំ....**
**របស់រដ្ឋបាលរាជធានី ខេត្ត ខណ្ឌឬ អង្គភាពថវិកា...**

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ | ឥណទានថវិកាបើកផ្តល់សាច់ប្រាក់មុន | ឥណទានថវិកាទូទាត់ត្រង់ | ឥណទានថវិកាបើកផ្តល់សាច់ប្រាក់មុនលើកដំបូង |
|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២/៤ |
| ៦១ | | | សេវាកម្ម | | | | |
| | ៦១១២ | | សោហ៊ុយបេសកកម្មក្នុងប្រទេស | | | | |
| | | ៦១១២១ | សោហ៊ុយដឹកជញ្ជូន | | | | |
| | | ៦១១២២ | សោហ៊ុយបេសកកម្ម | | | | |
| | | ៦១១២៣ | សោហ៊ុយស្នាក់នៅ | | | | |
| | | ៦១១២៨ | សោហ៊ុយក្នុងប្រទេសផ្សេងៗ | | | | |
| | សរុប | | | | | | |

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ .... ខែ .... ឆ្នាំ ..... ព.ស.
..., ថ្ងៃទី .. ខែ .. ឆ្នាំ ..
ប្រធានរតនាគាររាជធានី
ខេត្ត...

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ ... ខែ ... ឆ្នាំ ... ព.ស.
..., ថ្ងៃទី... ខែ .. ឆ្នាំ ..
ប្រធានមន្ទីរសេដ្ឋកិច្ចនិង
ហិរញ្ញវត្ថុរាជធានី ខេត្ត...

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ ... ខែ .... ឆ្នាំ .... ព.ស.
..., ថ្ងៃទី .. ខែ .. ឆ្នាំ..
នាយកទីចាត់ការហិរញ្ញវត្ថុ
/ប្រធានការិយាល័យ...

ថ្ងៃ .. ខែ .. ឆ្នាំ.. ព.ស.
..., ថ្ងៃទី .. ខែ.. ឆ្នាំ ..
រដ្ឋលេខាធិការ/អភិបាល...

បានឃើញនិងឯកភាព
ថ្ងៃ ...... ខែ ...... ឆ្នាំ ........ ព.ស...
........., ថ្ងៃទី ......... ខែ ......... ឆ្នាំ .........
អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត/ខណ្ឌ

**ឧបសម្ពន្ធទី១.៣ (សម្រាប់រដ្ឋបាលក្រុង ស្រុក)**

(ឧបសម្ពន្ធភ្ជាប់ប្រកាសលេខ....................... ចុះថ្ងៃទី....... ខែ.......... ឆ្នាំ......... ស្តីពីវិធាននិងនីតិវិធីចំណាយ
ប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ )

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**រដ្ឋបាលក្រុង ស្រុក...**

**គម្រោងចំណាយប្រាក់បេសកកម្មតាមចំណាត់ថ្នាក់សេដ្ឋកិច្ចសម្រាប់ឆ្នាំ....**
**របស់រដ្ឋបាលក្រុង ស្រុក ...**

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ | ឥណទានថវិកាបើកផ្តល់សាច់ប្រាក់មុន | ឥណទានថវិកាទូទាត់ត្រង់ | ឥណទានថវិកាបើកផ្តល់សាច់ប្រាក់មុនលើកដំបូង |
|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២/៤ |
| ៦១ | | | សេវាកម្ម | | | | |
| | ៦១១២ | | សោហ៊ុយបេសកកម្មក្នុងប្រទេស | | | | |
| | | ៦១១២១ | សោហ៊ុយដឹកជញ្ជូន | | | | |
| | | ៦១១២២ | សោហ៊ុយបេសកកម្ម | | | | |
| | | ៦១១២៣ | សោហ៊ុយស្នាក់នៅ | | | | |
| | | ៦១១២៤ | សោហ៊ុយក្នុងប្រទេសផ្សេងៗ | | | | |
| | សរុប | | | | | | |

បានឃើញនិងឯកភាព
ថ្ងៃ ... ខែ ... ឆ្នាំ ... ព.ស.
........., ថ្ងៃទី... ខែ .. ឆ្នាំ ..
ប្រធានរតនាគារជាតិ ខេត្ត...

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ ... ខែ .... ឆ្នាំ .... ព.ស...
........., ថ្ងៃទី .. ខែ .. ឆ្នាំ..
ប្រធានាការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ

ថ្ងៃ .. ខែ ... ឆ្នាំ ... ព.ស...
... ថ្ងៃទី .. ខែ.. ឆ្នាំ ..
រដ្ឋលេខាធិការប្រុបប្រទាន

បានឃើញនិងឯកភាព
ថ្ងៃ ... ខែ ... ឆ្នាំ ... ព.ស.
........., ថ្ងៃទី... ខែ .. ឆ្នាំ ..
អភិបាលនៃគណៈអភិបាលក្រុង ស្រុក

## ឧបសម្ព័ន្ធទី១.៤ (សម្រាប់រដ្ឋបាលឃុំ សង្កាត់)

(ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ........................ ចុះថ្ងៃទី....... ខែ.......... ឆ្នាំ......... ស្តីពីវិធាននិងនីតិវិធីចំណាយ ប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ )

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានី ខេត្ត................**

**ឃុំ សង្កាត់..................**

### គម្រោងចំណាយប្រាក់បេសកកម្មតាមចំណាត់ថ្នាក់សេដ្ឋកិច្ចសម្រាប់ឆ្នាំ...
### របស់រដ្ឋបាលឃុំ សង្កាត់...

| ជំពូក | គណនី | អនុគណនី | ឃរិយាយ | ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ... | ឥណទានថវិកាបើកផ្តល់សាច់ប្រាក់មុន | ឥណទានថវិកាទូទាត់ត្រង់ | ឥណទានថវិកាបើកផ្តល់សាច់ប្រាក់មុនលើកដំបូង |
|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២/៤ |
| ៦១ | | | សេវាកម្ម | | | | |
| | ៦១១២ | | សោហ៊ុយបេសកកម្មក្នុងប្រទេស | | | | |
| | | ៦១១២១ | សោហ៊ុយដឹកជញ្ជូន | | | | |
| | | ៦១១២២ | សោហ៊ុយបេសកកម្ម | | | | |
| | | ៦១១២៣ | សោហ៊ុយស្នាក់នៅ | | | | |
| | | ៦១១២៨ | សោហ៊ុយក្នុងប្រទេសផ្សេងៗ | | | | |
| | សរុប | | | | | | |

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ ......ខែ ......ឆ្នាំ ........ ព.ស.
.........ថ្ងៃទី ..ខែ ..ឆ្នាំ ..
ប្រធានរតនាគាររាជធានី ខេត្ត...

បានឃើញនិងឯកភាព
ថ្ងៃ ...ខែ ....ឆ្នាំ .... ព.ស.
........., ថ្ងៃទី ..ខែ ..ឆ្នាំ..
មេឃុំ/ ចៅសង្កាត់...

ថ្ងៃ ..ខែ ...ឆ្នាំ ... ព.ស.
...ថ្ងៃទី ..ខែ..ឆ្នាំ ..
រដ្ឋលេខាធិការប្រធាន

**ឧបសម្ព័ន្ធទី១.៥**

(ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ...................... ចុះថ្ងៃទី....... ខែ.......... ឆ្នាំ......... ស្ដីពីវិធាននិងនីតិវិធីចំណាយ

ប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានី ខេត្ត / អង្គភាពថវិកា÷** .................

**រដ្ឋបាលខណ្ឌ** ÷ .................

**គម្រោងចំណាយប្រាក់បេសកកម្មតាមចំណាត់ថ្នាក់កម្មវិធីប្រចាំឆ្នាំ.....**
**របស់រដ្ឋបាលរាជធានី ខេត្ត / អង្គភាពថវិកា / រដ្ឋបាលខណ្ឌ ...**

| **ចំណាត់ថ្នាក់កម្មវិធី** | **សរុបរួម** | | | ៦១១២១ "សោហ៊ុយដឹកជញ្ជូន" | | | ៦១១២២ "សោហ៊ុយបេសកកម្ម" | | | ៦១១២៣ "សោហ៊ុយស្នាក់នៅ" | | | ៦១១២៨ "សោហ៊ុយក្នុងប្រទេសផ្សេងៗ" | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ឥណទាន ថវិកា បើកផ្ដល់សាច់ប្រាក់មុន | ឥណទាន ថវិកា ទូទាត់ត្រង់ | សរុប | ឥណទាន ថវិកា បើកផ្ដល់សាច់ប្រាក់មុន | ឥណទាន ថវិកា ទូទាត់ត្រង់ | សរុប | ឥណទាន ថវិកា បើកផ្ដល់សាច់ប្រាក់មុន | ឥណទាន ថវិកា ទូទាត់ត្រង់ | សរុប | ឥណទាន ថវិកា បើកផ្ដល់សាច់ប្រាក់មុន | ឥណទាន ថវិកា ទូទាត់ត្រង់ | សរុប | ឥណទាន ថវិកា បើកផ្ដល់សាច់ប្រាក់មុន | ឥណទាន ថវិកា ទូទាត់ត្រង់ |
| **សរុប** | | | | | | | | | | | | | | | |
| កម្មវិធីទី១... | | | | | | | | | | | | | | | |
| អនុកម្មវិធីទី១... | | | | | | | | | | | | | | | |
| ចង្កោមសកម្មភាពទី១... | | | | | | | | | | | | | | | |
| ............. | | | | | | | | | | | | | | | |
| អនុកម្មវិធីទី២... | | | | | | | | | | | | | | | |
| ............. | | | | | | | | | | | | | | | |
| កម្មវិធីទី២... | | | | | | | | | | | | | | | |
| ............. | | | | | | | | | | | | | | | |

បានឃើញនិងឯកភាព
ថ្ងៃ.............ខែ ......ឆ្នាំ ........ ព.ស.
........., ថ្ងៃទី .........ខែ .........ឆ្នាំ .........
អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត/ខណ្ឌ

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ.............ខែ....ឆ្នាំ .... ព.ស.
........., ថ្ងៃទី ..ខែ ..ឆ្នាំ..
នាយកទីចាត់ការហិរញ្ញវត្ថុ/ប្រធានការិយាល័យ...

ថ្ងៃ............ខែ.........ឆ្នាំ... ព.ស.
........., ថ្ងៃទី ..ខែ..ឆ្នាំ ..
រដ្ឋលេខាធិការ/ប្រធាន

## ឧបសម្ព័ន្ធទី២

(ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ........................ ចុះថ្ងៃទី....... ខែ.......... ឆ្នាំ......... ស្តីពីរបៀបនិងនីតិវិធីចំណាយ
ប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ )

**រដ្ឋបាលរាជធានី ខេត្ត / អង្គភាពថវិកា÷** ..................
**រដ្ឋបាលក្រុង ស្រុក ខណ្ឌ÷** ..................
**រដ្ឋបាលឃុំ សង្កាត់÷** ..................

**របាយការណ៍ចំណាយប្រាក់បេសកកម្មចាប់ពីថ្ងៃទី...........ខែ..........ឆ្នាំ........ ដល់ថ្ងៃទី.............ខែ...........ឆ្នាំ...........**

| ល.រ | គោត្តនាម នាម | លិខិតបេសកកម្ម | | កម្មវត្ថុនៃការចុះបេសកកម្ម | ទីកន្លែង | កាលបរិច្ឆេទចុះបេសកកម្ម | | ចំនួនថ្ងៃ | ចំនួនយប់ | សោហ៊ុយធ្វើដំណើរ | ប្រាក់ហោប៉ៅ | | ប្រាក់ហូបចុក | | ប្រាក់ស្នាក់នៅ | | ទឹកប្រាក់សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | លេខ | កាលបរិច្ឆេទ | | | ចាប់ផ្តើម | ត្រលប់ | | | | របប | សរុប | របប | សរុប | របប | សរុប | |
| | | | | | | | | ១ | ២ | ៣ | ៤ | ៥=១x៤ | ៦ | ៧=១x៦ | ៨ | ៩=២x៨ | ១០=៣+៥+៧+៩ |
| | | | | | | | | | | | | | | | | | |
| ១ | | | | | | | | | | | | | | | | | |
| ២ | | | | | | | | | | | | | | | | | |
| | | | | | | | | | សរុប | | | | | | | | |

ចំនួនទឹកប្រាក់សរុប...............................................(ជាអក្សរ...........................................................)។

បានឃើញនិងឯកភាព
ថ្ងៃ..............ខែ ......ឆ្នាំ ........ ព.ស.
.........., ថ្ងៃទី .........ខែ .........ឆ្នាំ .........
អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត/ក្រុង ស្រុក
ខណ្ឌ/មេឃុំ ចៅសង្កាត់

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ..............ខែ....ឆ្នាំ .... ព.ស.
........., ថ្ងៃទី ..ខែ..ឆ្នាំ..
នាយកទីចាត់ការហិរញ្ញវត្ថុ/ប្រធានការិយាល័យ...

ថ្ងៃ.............ខែ.........ឆ្នាំ... ព.ស.
........., ថ្ងៃទី ..ខែ..ឆ្នាំ ..
រដ្ឋលេខាធិការ/អនុប្រធាន

**ឧបសម្ព័ន្ធទី៣**

(ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ....................... ចុះថ្ងៃទី....... ខែ.......... ឆ្នាំ......... ស្តីពីវិធាននិងនីតិវិធីចំណាយ ប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានី ខេត្ត...**

**រដ្ឋបាលក្រុង ស្រុក ខណ្ឌ... /មន្ទីរសុខាភិបាលខេត្ត.../ទីភ្នាក់ងារប្រតិបត្តិការពិសេស...**

**រដ្ឋបាលឃុំ សង្កាត់...**

លេខ÷

ថ្ងៃ... ... ...ខែ ...... ឆ្នាំ... ...ស័ក ព.ស. ....

រាជធានីភ្នំពេញ/ខេត្ត..., ថ្ងៃទី... ខែ...ឆ្នាំ...

**គោរពជូន**

**លោក លោកស្រី ប្រធានរតនាគាររាជធានី ខេត្ត**

**កម្មវត្ថុ÷** សំណើសុំដកប្រាក់សោហ៊ុយបេសកកម្មចំនួន..........................ដើម្បីបំពេញឡើងវិញនូវថវិកាដែលបានចំណាយ។

**យោង÷** អាណត្តិបើកប្រាក់លេខ... ... ...ចុះថ្ងៃទី ... ខែ... ឆ្នាំ......

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោក លោកស្រី** មេត្តាជ្រាបថា÷ រដ្ឋបាលខេត្ត.../រដ្ឋបាលក្រុង ស្រុក ខណ្ឌ... /មន្ទីរសុខាភិបាលខេត្ត... /ទីភ្នាក់ងារប្រតិបត្តិការពិសេស.../រដ្ឋបាលឃុំ សង្កាត់... បានចំណាយប្រាក់សោហ៊ុយបេសកកម្ម ចំនួន....................... នៃចំនួនទឹកប្រាក់សរុបដែលបានបើកផ្តល់មុនចំនួន....................ក្នុងមួយជុំបង្វិល។ ដោយមានតម្រូវការចំណាយជាក់ស្តែងបន្តទៀត សូមស្នើរតនាគាររាជធានី ខេត្ត.... បើកប្រាក់បំពេញឡើងវិញនូវថវិកាដែលបានចំណាយរួច ចំនួន .................. ដោយផ្ទេរចូលគណនីរបស់រដ្ឋទេយ្យករបុរេប្រទាន លេខ ............................ នៅធនាគារ.......................។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោក លោកស្រី** មេត្តាពិនិត្យ និងសម្រេចបើកផ្តល់តាមការគួរ។

សូម **លោក លោកស្រី** មេត្តាទទួលនូវការគោរព ពីខ្ញុំ

**ហត្ថលេខា និងត្រា**

អាណាប័ក/អាណាប័កផ្ទេរសិទ្ធិ

## ឧបសម្ព័ន្ធទី៤

(ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ...................... ចុះថ្ងៃទី...... ខែ.......... ឆ្នាំ......... ស្តីពីរបបនិងនីតិវិធីចំណាយ
ប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ)

**តារាងបែងចែកភូមិសាស្ត្រជាតំបន់ និងប្រទេសក្នុងតំបន់សម្រាប់គិតប្រាក់បេសកកម្មក្រៅប្រទេសរបស់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ក្រោមជាតិ**

| តំបន់ | ប្រទេសក្នុងតំបន់ | ក្រុមទី ១ | ក្រុមទី ២ | ក្រុមទី ៣ |
|---|---|---|---|---|
| អាស៊ី | អាស៊ីកណ្តាល | | កាហ្សាក់ស្ថាន- កៀហ្ស៊ីស៊ីស្ថាន- តាហ្ស៊ីគីស្ថាន តួកម៉េនីស្ថាន- អ៊ូសបេគីស្ថាន | |
| | អាស៊ីខាងកើត | | ចិន- ហុងកុង- កូរ៉េខាងជើង- ម៉ាកាវ- ម៉ុងហ្គោលី | ជប៉ុន- កូរ៉េខាងត្បូង |
| | អាស៊ីខាងត្បូង | អាហ្វហ្គានីស្ថាន- បង់ក្លាដែស- ប៊ូតង់- ឥណ្ឌា អ៊ីរ៉ង់- ម៉ាល់ឌីវ- នេប៉ាល់- ប៉ាគីស្ថាន- ស្រីលង្កា | | |
| | អាស៊ីអាគ្នេយ៍ | ឥណ្ឌូណេស៊ី- ឡាវ- ម៉ាឡេស៊ី- មីយ៉ាន់ម៉ា ហ្វីលីពីន- ទីម័រខាងកើត- ថៃ- វៀតណាម | ព្រុយណេ- សិង្ហបុរី | |
| | អាស៊ីខាងលិច | | អាមេនី- អាស៊ែបៃហ្សង់- បារ៉ែន- ស៊ីប- ហ្សកហ្ស៊ី អ៊ីរ៉ាក់- អ៊ីស្រាអែល- ហ្ស៊កដានី- កូវ៉ែត- លីបង់ អូម៉ង់- កាតា- អារ៉ាប៊ីសាអូឌីត- ស៊ីរី- តួកគី- អេមីរ៉ាត អារ៉ាប់រួម- វែសបង់- យេម៉ែន | |
| អឺរ៉ុប | អឺរ៉ុបខាងជើង | | | ដាណឺម៉ាក- អេស្តូនី- ហ្វាំងឡង់- អ៊ីស្លង់- អៀរឡង់- ឡេតូនី លីទុយអានី- ន័រវែស- ស៊ុយអែត- ចក្រភពអង់គ្លេស |
| | អឺរ៉ុបខាងត្បូង | | អាល់បានី- បូស្នីនិងហឺហ្សេហ្គូវីណា- ក្រូអាស៊ី ហ្ស៊ីបាល់តា- ក្រិក- ម៉ាសេដ្វាន- ម៉ាល់ត៍ ម៉ុងតេណេហ្គ្រោ- សែប៊ី - ស្លូវេនី | |
| | អឺរ៉ុបខាងលិច | | | អូទ្រីស- បែលហ្ស៊ិក- បារាំង- អាល្លឺម៉ង់- លុចសំបួ |

| | | | | |
|---|---|---|---|---|
| | | | | ម៉ូណាកូ- ហូឡង់- ស៊ុីស |
| | អឺរ៉ុបខាងកើត | | បេឡារុស- ប៊ុលហ្គារី- ឆែក- ហុងគ្រី- ម៉ុលដាវី ប៉ូឡូញ- រ៉ូម៉ានី- អ៊ុយក្រែន | រុស្ស៊ី |
| អាមេរិក |ការ៉ាបៀន | | អង់ហ្គីឡា- អង់ទីហ្គា- អេរ៉ាប៊ែ- បាហាម៉ា កោះអង់គ្លេសវឺហ្ស៊ីន- កោះកៃម៉ាន- គុយបា ដូមីនីក- សាធារណរដ្ឋដូមីនីក- ហ្គ្រើណាដ ហ្សាម៉ាអ៊ីក- ហៃទី- ម៉ុងសេរ៉ា- ព័ត្វរីកូ- សាំងលូស៊ី សាំងវីនសង់ និងហ្គ្រើណាឌីន- គ្រីនីដាត តូបាហ្គោ- ទួក និងខេខឺស | |
| | អាមេរិកកណ្ដាល | | បេលី - កូស្តារីកា - អែលសាល់វ៉ាឌ័រ ក្វាតេម៉ាឡា- ហុងឌូរ៉ាស់ - ម៉ិកស៊ិក - នីការ៉ាហ្គា ប៉ាណាម៉ា | |
| | អាមេរិកខាងជើង | | | ប៊ឺមុដា - កាណាដា - សហរដ្ឋអាមេរិក |
| | អាមេរិកខាងត្បូង | | អាហ្សង់ទីន - បូលីវី - ប្រេស៊ីល - ស៊ីលី - កូឡុំប៊ី អេក្វាទ័រ - ហ្គីយ៉ាន - ប៉ារ៉ាហ្គាយ - ប៉េរូ ស៊ូរីណាម - វេណេស៊ុយអេឡា - អ៊ុយរូហ្គាយ | |
| អាហ្វ្រិក | អាហ្វ្រិកខាងកើត | | ប៊ូរុនឌី - កូម័រ - ជីប៊ូទី - អេត្យូពី - អេរីត្រេ កេនយ៉ា - ម៉ាដាហ្គាស្កា - ម៉ាឡាវី - ម៉ូរីស ម៉ូសំប៊ិក - រវ៉ាន់ដា - សីស្ហែល - សូម៉ាលី ស៊ូដង់ខាងត្បូង - តង់សានី - អ៊ូហ្គង់ដា - សំប៊ី ស៊ីមបាវ៉េ | |
| | អាហ្វ្រិកកណ្ដាល | | អង់ហ្គោឡា - ឆាដ - កាមេរូន - អាហ្វ្រិកកណ្ដាល កុងហ្គោ - ហ្គីណេ - អេក្វាទ័រ - ហ្គាបុង សៅតូម៉េ និងប្រាំងស៊ីប | |

| | | | | |
|---|---|---|---|---|
| | **អាហ្វ្រិកខាងជើង** | | អាល់ហ្សេរី - អេហ្ស៊ីប - លីប៊ី - ម៉ារ៉ុក - ស៊ូដង់ ទុយនីស៊ី | |
| | **អាហ្វ្រិកខាងត្បូង** | | បុតស្វាណា - ឡេសូតូ - ណាមីប៊ី - ស្វាស៊ីឡង់ | អាហ្វ្រិកខាងត្បូង |
| | **អាហ្វ្រិកខាងលិច** | | បេណាំង - បួគីណាហ្វាសូ - កោះខែនណារី កាប់វែរ - កូតឌីវ័រ - ហ្គំប៊ី - ហ្គាណា - ហ្គីណេ ហ្គីណេប៊ីស្សូ - លីបេរីយ៉ា - ម៉ូរីតានី - ម៉ាលី នីហ្សេរីយ៉ា - សេណេហ្គាល់ - សៀរ៉ាលីអូន តូហ្គោ | |
| **អូសេអានី** | | | អាមេរិកសាម័រ - កោះយុក - ហ្វីជី - គីរីបាទី មីក្រូណេស៊ី - នៃអៀរ - ណូរូ - ផាឡាវ ប៉ាពួអាស៊ីនូវែលហ្គីណេ - សាម័រ - កោះសូឡូម៉ូន តុងហ្គា - វ៉ានូទូ - ទូវ៉ាលូ | អូស្ត្រាលី - នូវែលសេឡង់ |